តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្ដីពី
ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្ម
ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០៣/១៦-១២-២០១១/អវតក/អបជ

**ចំពោះមុខ:** **ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន**
**ចៅក្រម Rowan DOWNING**
**ចៅក្រម នីយ ថុល**
**ចៅក្រម Chang-Ho CHUNG**
**ចៅក្រម ហួត វុទ្ធី**

**កាលបរិច្ឆេទ:** ថ្ងៃទី ខែកុម្ភៈ ឆ្នាំ២០១២

---

**សាធារណៈ: សំណៅកោសលប់**

# យោបល់របស់ចៅក្រម Rowan DOWNING និងចៅក្រម Chang-Ho CHUNG នៃអង្គបុរេជំនុំជម្រះស្ដីពីការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ដោយអនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង

---

**<u>សហចៅក្រមស៊ើបអង្កេត</u>**

យូ ប៊ុនឡេង

Laurent KASPER-ANSERMET

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង

Andrew CAYLEY

**<u>ការិយាល័យរដ្ឋបាល</u>**

ក្រាញ់ តូនី

Knut ROSANDHAUG

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួលកំណត់ហេតុស្តីពីការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង និងសហចៅក្រមស៊ើបអង្កេតជាតិ ដែលត្រូវបានបញ្ជូនបន្តដោយការិយាល័យរដ្ឋបាល ដោយអនុលោមតាមវិធាន ៧២ ដោយហេតុថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ស្នើសុំចេញដីកាសម្រេចស្តីពីការបើកការស៊ើបអង្កេតបឋមឡើងវិញលើសំណុំរឿង ០០៣/០៧-០៩-២០០៩/អ.វ.ត.ក/ក.ស.ច.ស ហើយដីកានេះត្រូវបានសហចៅក្រមស៊ើបអង្កេតជាតិជំទាស់ ("ការខ្វែងយោបល់គ្នា")[១]។

## I. ប្រវត្តិនីតិវិធី និងសារណា

១. បន្ទាប់ពីអង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួន ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាទាំងពីររូប ដោយអនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ អតីតសហព្រះរាជអាជ្ញាស្តីទី បានដាក់ជាសម្ងាត់នូវ "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២ [redacted]"[២] ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ") ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយស្នើឱ្យសហចៅក្រមស៊ើបអង្កេតចាប់ផ្តើមបំពេញកិច្ចស៊ើបសួរលើសំណុំរឿង០០៣។ កាលពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១០ លោកចៅក្រម Laurent Kasper-Ansermet ត្រូវបានព្រះមហាក្សត្រនរោត្តម សីហមុនី តែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង[៣] ហើយកាលពីថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១ លោកចៅក្រម Laurent Kasper-Ansermet បានស្បថចូលកាន់តំណែងនៅក្នុងអំឡុងកិច្ចប្រជុំពេញអង្គ

---

[1] កំណត់ហេតុនៃការខ្វែងយោបល់គ្នា ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១។

[2] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារលេខ D1/1។

[3] សេចក្តីប្រកាសព័ត៌មាន "លោកបណ្ឌិត Siegfried Blunk ត្រូវបានតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី" ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១០ ដែលមាននៅលើគេហទំព័រ http://www.eccc.gov.kh/sites/default/files/media/ECCC_1_Dec_2010_(Eng).pdf។

អ.វ.ត.ក[4]។ ហេតុការណ៍ទាំងនេះត្រូវបានកត់ត្រាទុកជាកំណត់ហេតុសាធារណៈ។

២. កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ[5]។

៣. កាលពីថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបី[6] ( ដែលហៅជារួមថា "សំណើសុំបំពេញកិច្ចស៊ើបសួរ") ដោយបានបង្ហាញឯកសារបន្ថែម ដែលត្រូវផ្ទេរចេញពីសំណុំរឿង០០២ ទៅសំណុំរឿង ០០៣ ព្រមទាំងឯកសារថ្មីៗដទៃទៀត និងស្នើឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម ទាក់ទិននឹងទីកន្លែងប្រព្រឹត្តបទល្មើសដែលត្រូវបានចោទប្រកាន់ ហេតុការណ៍នៃឧក្រិដ្ឋកម្ម និងការទទួលខុសត្រូវរបស់ជនសង្ស័យ ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

៤. កាលពីថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញ "ដីកាសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣" "ដីកាសម្រេច"[7] ដោយបានច្រានចោលសំណើនោះ និងលើកឡើងថា សំណើនោះមិនមានសុពលភាពដោយសំអាងថាវិធានផ្ទៃក្នុង "មិនបានទុកចន្លោះណាមួយសម្រាប់ឲ្យសហព្រះរាជអាជ្ញាមួយរូប អាចបំពេញកិច្ចជាលក្ខណៈបុគ្គលបានឡើយ លើកលែងតែមានសេចក្តី

---

[4] សុន្ទរកថាជាសាធារណៈរបស់ឯកឧត្តម គង់ ស្រ៊ឹម ប្រធានអង្គជំនុំជម្រះតុលាការកំពូល ក្នុងពេលបើកកិច្ចប្រជុំពេញអង្គរបស់ អ.វ.ត.ក នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១។

[5] សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D13។

[6] សំណើបំពេញកិច្ចស៊ើបសួរលើកទីមួយរបស់សហព្រះរាជអាជ្ញាអន្តជាតិ ក្នុងសំណុំរឿងលេខ០០៣ សុំឲ្យទទួលយកឯកសារបន្ថែម និងសេចក្តីសង្ខេបនៃកិច្ចស៊ើបសួរ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០១១ ឯកសារលេខ D17 ("សំណើកិច្ចបំពេញស៊ើបសួរលើកទីមួយ"), សំណើលើកទីពីររបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងលោក ស៊ូ ម៉េត និងពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ D18 ("សំណើកិច្ចបំពេញស៊ើបសួរលើកទីពីរ"), សំណើលើកទីបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងលោក មាស មុត និងពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ D19 ("សំណើកិច្ចបំពេញស៊ើបសួរលើកទីបី")។

[7] ដីកាសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ D20/3។

សម្រេចផ្ទេរអំណាច ដែលត្រូវធ្វើឡើងស្របតាមវិធាន ១៣ (៣) ឬកំណត់ហេតុនៃការខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា ដែលធ្វើឡើងស្របតាមវិធាន ៧១ (១)"។

៥. កាលពីថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនោះ ("បណ្តឹងឧទ្ធរណ៍")[8]។ នៅថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួន ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិថា៖

"ទោះបីជាមានការខិតខំប្រឹងប្រែងយ៉ាងណាក្តី អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រជាវិជ្ជមានបានឡើយ ពីចៅក្រមបួនរូបយ៉ាងតិច ដែលចាំបាច់អាចចេញសេចក្តីសម្រេចមួយលើខ្លឹមសារនៃបណ្តឹងឧទ្ធរណ៍នេះ ឬលើការទទួលយកបណ្តឹងឧទ្ធរណ៍នេះ។ ដោយហេតុថា វិធាន៧៧(១៤) នៃវិធានផ្ទៃក្នុងចែងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះត្រូវមានសំអាងហេតុនោះ មតិផ្សេងៗរបស់ចៅក្រមអង្គជំនុំជម្រះមានភ្ជាប់មកជាមួយសេចក្តីពិចារណាទាំងនេះ។

ដោយហេតុថា អង្គបុរេជំនុំជម្រះមិនបានសម្រេចលើបណ្តឹងឧទ្ធរណ៍នេះ វិធាន៧៧(១៣) នៃវិធានផ្ទៃក្នុងចែងថា ដីកាដែលត្រូវបានជំទាស់នោះត្រូវតម្កល់ទុកជាបានការ"[9]។

៦. កាលពីថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្តីប្រកាសព័ត៌មានមួយដោយបានលើកឡើងថា "ដោយសារតែការលើកឡើងម្តងហើយម្តងទៀត [ពីសំណាក់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ទាក់ទិននឹងការចេញសេចក្តីថ្លែងនានាហាមឃាត់មិនឱ្យស៊ើបអង្កេតបន្ថែម] ដែលនឹងធ្វើឱ្យមានការយល់ឃើញថា ជាការប៉ុនប៉ងជ្រៀតជ្រែករបស់មន្ត្រីរដ្ឋាភិបាលនៅក្នុងដំណើរការសំណុំរឿង០០៣ និង០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កាលពីថ្ងៃទី ០៨

---

[8] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ជំទាស់នឹង "សេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣" ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារលេខ D20/4/1 (សំណៅឯកសារសម្ងាត់) និង ឯកសារលេខ D20/4.2(សំណៅដែលមានលុបផ្នែកខ្លះ)។

[9] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងដីកាសម្រេចស្តីពីសំណើសុំពន្យាពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ D20/4/4 កថាខណ្ឌ១៣ និង ១៤។

ខែ តុលា ឆ្នាំ ២០១១[១០] បានបញ្ជូនពាក្យសុំលាឈប់ពីតួនាទីរបស់ខ្លួនទៅលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ"។ ការលាឈប់ពីតំណែងរបស់ចៅក្រមរូបនោះ បានចូលជាធរមាននៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១១។

៧. កាលពីថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង បានបញ្ជូនឯកសារព្រាងមួយដែលមានចំណងជើងថា "ដីកាសម្រេចស្តីពីការបើកស៊ើបអង្កេតបឋមឡើងវិញ" លើសំណុំរឿង០០៣[១១] (ដីកាសម្រេចដែលត្រូវបានស្នើឡើង) ទៅកាន់សហចៅក្រមស៊ើបអង្កេតជាតិ ដោយស្នើឱ្យសហចៅក្រមស៊ើបអង្កេតជាតិពិនិត្យ និងចុះហត្ថលេខាដើម្បីចេញដីកាសម្រេចនោះ។ ផ្អែកលើការពិចារណាឡើងវិញលើសេចក្តីសម្រេចមុនៗ ដីកាសម្រេចដែលត្រូវបានស្នើឡើងសម្រេចទទួលយកសំណើសុំបំពេញកិច្ចស៊ើបសួរ ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់។ កាលពីថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតជាតិបានឆ្លើយតបទៅសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងតាមរយៈអនុស្សរណៈផ្ទៃក្នុង ដោយបញ្ជាក់ថា ខ្លួនបានទទួលលិខិត និងដីកាដែលត្រូវបានស្នើឡើងនោះហើយ។ អនុស្សរណៈនោះក៏បានទទួលស្គាល់ថា "ដោយមានជំនួយពីមន្ត្រីរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតជាតិអាចយល់បានថា ឯកសារទាំងនេះជាឯកសារស្តីពីខ្លឹមសារនៃកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង" ហើយសហចៅក្រមស៊ើបអង្កេតជាតិ "អាចពិភាក្សាអំពីខ្លឹមសារ នៃកិច្ចដំណើរការនីតិវិធីជាមួយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបាន លុះត្រាតែសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ទទួលបានការតែងតាំងជាផ្លូវការដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជាជាមុនសិន"។

៨. កាលពីថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានចេញសេចក្តីប្រកាសព័ត៌មានដូចខាងក្រោម៖

---

[10] សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១ http://www.eccc.gov.h/sites/default/files/media/correctedECCC-INTCIJ%2010%20Oct%202011%20(Eng).pdf ។

[11] សូមមើលឯកសារភ្ជាប់ទី៤.១ ទៅនឹងកំណត់ហេតុស្តីពីការខ្វែងយោបល់ "ដីកាសម្រេចស្តីពីការបើកស៊ើបអង្កេតបឋមឡើងវិញ" ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១ ("ដីកាសម្រេចដែលត្រូវបានស្នើឡើង")។

“សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង”

ដោយបានទទួលការតែងតាំងតាមរយៈព្រះរាជក្រឹត្យចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ឲ្យមកបំពេញការងារនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) សម្រាប់រយៈពេលនៃកិច្ចដំណើរការនីតិវិធីទាំងមូល ដោយទទួលបានការយល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជា និងបន្ទាប់ពីបានស្បថនៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១ <u>បើយោងតាមច្បាប់</u> លោកសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ជំនួសចៅក្រមមុន និងទទួលកាន់តួនាទីរបស់ចៅក្រមមុន ក្រោយពេលដែលគាត់បានលាលែងពីតំណែងដោយគ្មានគ្រោងទុក ដោយមានប្រសិទ្ធភាពពីថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១១ (មាត្រា១២, ២៣, ២៦ និង ២៧ នៃច្បាប់ អ.វ.ត.ក)។

បន្ទាប់ពីបានបំពេញការងារតាមអាណត្តិរបស់ខ្លួន តាមមធ្យោបាយពីចម្ងាយពីប្រទេសក្រៅ តាំងពីថ្ងៃទី ១៤ ខែ វិច្ឆិកា ដោយអនុលោមតាមវិធាន១៤(៦) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក នាពេលបច្ចុប្បន្ន លោកសហចៅក្រមស៊ើបអង្កេតជាតិបម្រុងបានបំពេញការងារនៅការិយាល័យរបស់គាត់នៅទីក្រុងភ្នំពេញហើយ។ ក្នុងការគោរពតាមគោលការណ៍នៃការយកចិត្តទុកដាក់សមស្រប (វិធាន ២១.៤ នៃវិធានផ្ទៃក្នុង) សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង និងសហចៅក្រមជាតិនឹងចាត់ចែងបំពេញកិច្ចស៊ើបសួរ ព្រមទាំងចាត់វាល់វិធានការចាំបាច់នានា ដើម្បីគ្រប់គ្រងការិយាល័យរបស់ខ្លួន។

ដោយអនុលោមតាមវិធាន ៥៦(២) នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក លោកសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង និងសហចៅក្រមជាតិនឹងព្យាយាមផ្តល់ព័ត៌មានទៅសាធារណជនឲ្យបានគ្រប់គ្រាន់អំពីការវិវឌ្ឍន៍សំខាន់ៗនៅក្នុងសំណុំរឿង ០០៣ និង ០០៤”[១២]។

៩. តបទៅនឹងសេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង សហចៅក្រមស៊ើបអង្កេតជាតិបានចេញសេចក្តីថ្លែងការណ៍មួយ ដូចខាងក្រោមកាលពីថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ ៖

[12] សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ ដែលមាននៅលើគេហទំព័រ http://www.eccc.gov.kh/en/articles/statement-international-reserve-co-investigating-judge។

## សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតជាតិ

នៅថ្ងៃនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងលោក Laurent Kasper-Ansermet បានចេញសេចក្តីប្រកាសព័ត៌មានមួយ ដោយពុំបានពិគ្រោះជាមួយសហចៅក្រមស៊ើបអង្កេតជាតិ។ អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតជាតិសូមជម្រាបមតិជាតិ និងអន្តរជាតិឱ្យបានជ្រាបថា៖

១. បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Siegrfried Blunk បានលាឈប់កាលពីថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១១ រហូតមកទល់ពេលនេះ មិនទាន់មានការតែងតាំងសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មីជាផ្លូវការមកជំនួសនៅឡើយទេ។

២. ទន្ទឹមនឹងនេះ នៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតជាតិបានជួបសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងលោក Laurent Kasper-Ansermet នៅការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយបានជម្រាបលោក Laurent Kasper-Ansermet ថាដើម្បីធានានូវភាពត្រឹមត្រូវតាមផ្លូវច្បាប់ (ស្របតាមគោលការណ៍ដែលមានចែងក្នុងវិធាន ៧.៤ នៃវិធានផ្ទៃក្នុង មាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣ និងមាត្រា ៥.៦ នៃកិច្ចព្រមព្រៀង) ក៏ដូចជាការអនុវត្តជាមួយសហចៅក្រមស៊ើបអង្កេតអន្តរជាតិមុនៗកន្លងមក សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងត្រូវតែរង់ចាំទទួលបានការតែងតាំងជាផ្លូវការតាមនីតិវិធីជាធរមានជាមុនសិន មុននឹងចាប់ផ្តើមបំពេញការងាររបស់ខ្លួន។ ដូច្នេះចំណាត់ការនីតិវិធីផ្សេងៗរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងលោក Laurent Kasper-Ansermet មិនមានសុពលភាពគតិយុត្តិឡើយ[១៣]។

១០. កាលពីថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានដាក់កំណត់ហេតុនៃការខ្វែងយោបល់ និងឯកសារពាក់ព័ន្ធទៅការិយាល័យរដ្ឋបាល។ កាលពីថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១ អនុលោមតាមវិធាន ៧២ ប្រធានការិយាល័យរដ្ឋបាលស្តីទីបានបញ្ជូនឯកសារទាំងនេះទៅ

---

[13] សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតជាតិ (ឯកសារបកប្រែកៅផ្លូវការ) ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ ដែលមាននៅលើគេហទំព័រ http://www.eccc.gov.kh/sites/default/files/media/5-Corrected%20English%20version%20of%20Press%20Statement%20National%20CIJ%20December%206%20Final.pdf ។

ប្រធានអង្គបុរេជំនុំជម្រះ ដោយចម្លងជូនមួយច្បាប់ទៅសហចៅក្រមស៊ើបអង្កេតជាតិ។

១១. យើងកត់សម្គាល់ឃើញទៀតថា ក្នុងការពិភាក្សាលើមតិយោបល់របស់យើង យើងដឹងច្បាស់ថា សហចៅក្រមស៊ើបអង្កេតជាតិ អាចដាក់កំណត់ហេតុស្តីពីការខ្វែងយោបល់ទៅការិយាល័យរដ្ឋបាលក្នុងរយៈពេល១០ថ្ងៃ ដើម្បីធ្វើការឆ្លើយតប និងដាក់ទឡ្ហីករណ៍ជំទាស់ ឬទឡ្ហីករណ៍នានា ឆ្លើយតបទៅនឹងសារណា និងឯកសារអំណះអំណាងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នា និងបញ្ហាទាក់ទងនឹងតំណែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង[១៤]។ សហចៅក្រមស៊ើបអង្កេតជាតិបានសម្រេចមិនអនុវត្តដូច្នេះឡើយ ដោយហេតុថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង មិនបានទទួលឯកសារនានាដូចបានលើកខាងលើ[១៥]។

១២. នៅក្នុងសារណារបស់ខ្លួន សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានធ្វើការកត់សម្គាល់អំពី "អត្ថិភាពនៃការខ្វែងយោបល់ជាមួយសហចៅក្រមស៊ើបអង្កេតជាតិ ទាក់ទងនឹងភាពអាចទទួលយកបាននៃដីកាសម្រេចស្តីពីការបើកការស៊ើបអង្កេតបឋមឡើងវិញ សម្រាប់សំណុំរឿង០០៣ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១"។ នៅក្នុងកំណត់ហេតុនៃការខ្វែងយោបល់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងអះអាងថា សហចៅក្រមស៊ើបអង្កេតជាតិបានភ័ន្តច្រឡំអំពីលក្ខណៈ និងវិសាលភាពនៃនីតិវិធីក្នុងការតែងតាំងចៅក្រមនៅ អ.វ.ត.ក និងបានសន្និដ្ឋានថា "ដូចតាមការកំណត់ ចៅក្រមបម្រុងមានតួនាទីជំនួសចៅក្រមពេញសិទ្ធិ នៅក្នុងស្ថានភាពទាំងប៉ុន្មានដែលមានចែងក្នុងច្បាប់"។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងអះអាងទៀតថា "ជំហររបស់សហចៅក្រមស៊ើបអង្កេតជាតិនឹងធ្វើឱ្យគាំងស្ទះការងាររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត [...] ហើយដោយហេតុតែការចង់បញ្ចៀសការជាប់គាំងនេះឯង ទើបតំណែងសហចៅក្រមស៊ើបអង្កេតបម្រុងត្រូវ

---

[14] សូមមើល វិធាន ៧២.២ ។

[15] យើងកត់សម្គាល់ឃើញទៀតថា ដីកាដែលត្រូវបានស្នើឡើង អាចស្ថិតក្នុងវិសាលភាពនៃវិធាន ៧២(៤)(ប) ហើយអនុលោមតាមវិធាន ៧២ (២) កំណត់ត្រាស្តីពីការខ្វែងយោបល់ គប្បីត្រូវបានដាក់ក្នុងសំណុំរឿង និងជូនដំណឹងដល់ភាគីពាក់ព័ន្ធ ។ ទោះបីយ៉ាងណាមកទល់ពេលនេះ កំណត់ហេតុស្តីពីការខ្វែងយោបល់មិនត្រូវបានដាក់ទៅក្នុងសំណុំរឿង និងជូនដំណឹងដល់ភាគីពាក់ព័ន្ធឡើយ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាដែលជាប់ពាក់ព័ន្ធផ្ទាល់នឹងលទ្ធផលនៃនីតិវិធីនេះ មិនអាចដាក់សារណាបន្ថែមបានឡើយ។

បានបង្កើតឡើង" ហើយគោលជំហរបែបនេះគឺ "ជាការបំពានលើគោលការណ៍នៃការយកចិត្តទុកដាក់សមស្រប"។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងអះអាងទៀតថា ខ្លួនបានស្បថយ៉ាងត្រឹមត្រូវ កាលពីអំឡុងពេលនៃកិច្ចប្រជុំពេញអង្គរបស់ អ.វ.ត.ក នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១។ កំណត់ហេតុស្តីពីការខ្វែងយោបល់លើកឡើងថា ដីកាដែលត្រូវបានស្នើឡើង ដែលមានចំណាត់ថ្នាក់ជាឯកសារប្រភេទសម្ងាត់បំផុត និងដែលមានហត្ថលេខារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងកំណត់ហេតុស្តីពីការខ្វែងយោបល់ បានចេញនៅថ្ងៃដំណាលគ្នា។

## II. **ការបញ្ចេញមតិយោបល់ និងការសន្និដ្ឋាន**

១៣. យើងយល់ថា អង្គបុរេជំនុំជម្រះមានយុត្តាធិការលើកម្មវត្ថុនៃការខ្វែងយោបល់គ្នានេះ ដោយហេតុថាបញ្ហានេះពាក់ព័ន្ធនឹងភាពទទួលយកបាននៃដីកាដែលបានស្នើ "ដើម្បីបន្តការស៊ើបអង្កេតណាមួយ"[១៦] ដែលអនុលោមតាមមាត្រា៧ នៃកិច្ចព្រមព្រៀងស្តីពីការបង្កើតអ.វ.ត.ក "អង្គបុរេជំនុំជម្រះដែលមានសមាសភាពចៅក្រមចំនួន *ប្រាំរូប* ត្រូវដោះស្រាយជាបន្ទាន់"។

១៤. ថ្វីបើអង្គបុរេជំនុំជម្រះបានប្រឹងប្រែងយ៉ាងណាក៏ដោយ ក៏ខ្លួននៅពុំបានទទួលនូវសំឡេងគាំទ្រភាគច្រើនដែលខ្លួនត្រូវការដើម្បីសម្រេចថាតើចៅក្រម Kasper-Arsenet មានគុណវុឌ្ឍិក្នុងការដាក់កំណត់ហេតុស្តីពីការខ្វែងយោបល់គ្នានេះមកអង្គបុរេជំនុំជម្រះដែរ ឬយ៉ាងណា និងបានផ្អាកការពិភាក្សាសម្រេចលើកំណត់ហេតុស្តីពីការខ្វែងយោបល់គ្នានេះ។ ថ្វីបើដូច្នេះ ដោយពុំមានការជូនដំណឹងណាមួយស្តីពីខ្លឹមសារនៃការពិភាក្សាសម្រេច យើងក៏ត្រូវកត់សម្គាល់ដែរថា ការពិភាក្សាសម្រេចរបស់អង្គបុរេជំនុំជម្រះត្រូវអាក់ខាន ដោយសារតែមានហេតុការណ៍មួយចំនួនដូចខាងក្រោម៖

(i) កាលពីថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១២ តាមរយៈសារអេឡិចត្រូនិករបស់មន្ត្រីច្បាប់រងជាតិនៃអង្គបុរេជំនុំជម្រះ ចៅក្រមនៃអង្គបុរេជំនុំជម្រះបានដឹងថា ការពិភាក្សា

[16] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹងការកាត់សេចក្តីក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងរយៈកាល នៃសម័យកម្ពុជាប្រជាធិបតេយ្យ ចុះហត្ថលេខានៅថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣ (ចូលជាធរមាននៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥), ("កិច្ចព្រមព្រៀង") មាត្រា ៥(៤)។

សម្រេចនឹងធ្វើឡើងនៅថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១២ ពាក់ព័ន្ធនឹងកំណត់ហេតុនៃការខ្វែងយោបល់គ្នា។ មានការជូនដំណឹងមួយតាមរយៈសារអេឡិចត្រូនិកមួយទៀត កាលពីថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១២ ថាការពិភាក្សាសម្រេចដែលបានគ្រោងធ្វើនៅថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១២ ត្រូវបានលើកទៅថ្ងៃ សុក្រ ទី ២៧ ខែ មករា ឆ្នាំ ២០១២ វិញ។ នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ ចៅក្រមនៃអង្គបុរេជំនុំជម្រះបានធ្វើការពិភាក្សាសម្រេចលើកំណត់ហេតុនៃការខ្វែងយោបល់ ("ការពិភាក្សាសម្រេច")។ ក្រោយចប់ការពិភាក្សាសម្រេច អង្គបុរេជំនុំជម្រះបានផ្អាកការពិភាក្សាសម្រេចនេះ ដើម្បីទុកពេលពិចារណាលើបញ្ហានានា ដែលស្ថិតនៅចំពោះមុខខ្លួន។ កាលពីថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ចៅក្រម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះបានចេញអនុស្សរណៈអន្តរការិយាល័យមួយច្បាប់ផ្ញើទៅប្រធានការិយាល័យរដ្ឋបាលស្ដីទី ដោយបានគូសបញ្ជាក់ថា "អង្គបុរេជំនុំជម្រះបានលើកយកសំណុំឯកសារ (ពាក់ព័ន្ធនឹងកំណត់ហេតុនៃការខ្វែងយោបល់) ដើម្បីធ្វើការពិនិត្យពិចារណា ប៉ុន្តែចៅក្រមនៃអង្គបុរេជំនុំជម្រះពុំបានឯកភាពក្នុងការយកខ្លឹមសារនៃឯកសារទាំងនេះមកពិនិត្យពិចារណា"។ អនុស្សរណៈនេះបានកត់សម្គាល់ទៀតថា "ដោយយល់ឃើញថា លោក Laurent Kasper-Ansermet ពុំទាន់មានគុណសម្បត្តិគ្រប់គ្រាន់ក្នុងការបំពេញតួនាទីតាមនីតិវិធីច្បាប់ជាធរមាន ដូចនេះសំណុំឯកសារ.....ត្រូវបញ្ជូនត្រឡប់ទៅការិយាល័យរដ្ឋបាលវិញ"[១៧]។

(ii) នៅថ្ងៃដដែល យើងបានប្រាស្រ័យទាក់ទងការងារតាមរយៈអនុស្សរណៈមួយច្បាប់ដោយបានផ្ញើទៅប្រធានការិយាល័យរដ្ឋបាលស្ដីទី និងបានចម្លងជូនចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះដើម្បីឲ្យជ្រាបថា អនុស្សរណៈ ដែលមានហត្ថលេខារបស់ប្រធានអង្គបុរេជំនុំជម្រះ ដែលបញ្ជូនត្រឡប់មកវិញនូវឯកសារនានាពាក់ព័ន្ធនឹងកំណត់ហេតុនៃការខ្វែងយោបល់គ្នា ត្រូវបានចេញ មុនពេលមានការជូនដំណឹងមកចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ហើយអង្គបុរេជំនុំជម្រះនៅពុំទាន់បញ្ចប់ការពិភាក្សាសម្រេចរបស់ខ្លួននៅឡើយ

[17] អនុស្សរណៈអន្តរការិយាល័យរបស់ចៅក្រម ប្រាក់ គឹមសាន ផ្ញើជូនប្រធានការិយាល័យរដ្ឋបាលក្រោមកម្មវត្ថុ "បញ្ជូនត្រឡប់វិញនូវសំណុំឯកសារដែលការិយាល័យរដ្ឋបាលផ្ញើជូនអង្គបុរេជំនុំជម្រះ" ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ។

ទេ។ អនុស្សរណៈនេះបានធ្វើការកត់សម្គាល់ទៀតថា អនុស្សរណៈរបស់ចៅក្រម ប្រាក់ គីមសាន ពុំតំណាងឱ្យយោបល់ ឬសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះទាំងមូលឡើយ ហើយជាការបំពានគោលការណ៍រក្សាការសម្ងាត់ តាមរយៈការបង្កើបឱ្យសាធារណៈបានដឹងអំពីទស្សនៈរបស់ចៅក្រមមួយចំនួន នៃអង្គបុរេជំនុំជម្រះ នៅមុនពេលចប់ការពិភាក្សាសម្រេច។ អនុស្សរណៈរបស់យើងបានសន្និដ្ឋានថា អនុស្សរណៈរបស់ចៅក្រម ប្រាក់ គីមសាន ពុំមានអានុភាពគតិយុត្តិអ្វីមួយទៅលើលទ្ធផលនៃការខ្វែងយោបល់នោះឡើយ ហើយក្នុងករណីដែលនៅចុងបញ្ចប់នៃការពិភាក្សាសម្រេចរបស់ខ្លួន សេចក្ដីសម្រេចលើករណីខ្វែងយោបល់របស់អង្គបុរេជំនុំជម្រះ ពុំទទួលបានសំឡេងគាំទ្រភាគច្រើន ចៅក្រមត្រូវដាក់មតិយោបល់របស់ខ្លួន ទៅក្នុងសេចក្ដីពិចារណានៃរបស់អង្គបុរេជំនុំជម្រះទាំងមូលដូចដែលច្បាប់បានតម្រូវ។

១៥. ក្រោយពីយើងបានពិភាក្សាជាមួយចៅក្រម ប្រាក់ គីមសាន តាមទូរស័ព្ទ កាលពីថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ២០១២ និងបន្ទាប់ពីចៅក្រម ប្រាក់ គីមសាន បានបដិសេធពុំព្រមដកអនុស្សរណៈរបស់ខ្លួនដែលបានផ្ញើទៅប្រធានការិយាល័យ យើងគ្មានជម្រើសអ្វីក្រៅពីទទួលស្គាល់ថា អនុស្សរណៈរបស់ចៅក្រម ប្រាក់ គីមសាន គឺគ្រាន់តែជាយោបល់ផ្ទាល់ខ្លួនរបស់ចៅក្រម ប្រាក់ គីមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី ប៉ុណ្ណោះ។ ក្នុងអំឡុងពេលនៃការជជែកតាមទូរស័ព្ទ ចៅក្រម ប្រាក់ គីមសាន បានជម្រាបប្រាប់យើងថា ពួកគាត់ទាំងបីរូបបានចាត់ទុកថាបញ្ហានៃភាពទទួលយកបាននៃកំណត់ហេតុស្ដីពីការខ្វែងយោបល់ គឺជាបញ្ហារដ្ឋបាលប៉ុណ្ណោះ។ ពាក់ព័ន្ធនឹងចំណាត់ការរបស់ចៅក្រម ប្រាក់ គីមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី យើងត្រូវកំណត់បញ្ហានៃភាពទទួលយកបាននេះថា ជាការសម្រេចរបស់តុលាការ ស្របតាមសេចក្ដីសម្រេចមុនៗរបស់អង្គបុរេជំនុំជម្រះ[១៨] និងច្បាប់។ ឯកសារប្រភេទនេះពុំអាចត្រូវបានប្រគល់ត្រឡប់ទៅការិយាល័យរដ្ឋបាល ក្នុង

[18] សូមមើលសំណុំរឿងលេខ ០០៣/២៩-០៧-២០១១-អ.វ.ត.ក/(អ.ប.ជ ០១) សាលដីកាលើសំណើរបស់អង្គភាពគាំពារការការពារក្ដីឱ្យផ្អាកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០៣ នៅចំពោះមុខអង្គបុរេជំនុំជម្រះ និងសុំវិធានការពាក់ព័ន្ធនឹងការតំណាងជនសង្ស័យប្រកបដោយប្រសិទ្ធភាពក្នុងសំណុំរឿង០០៣ ឯកសារលេខ៣ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១។ សំណុំរឿងលេខ ០០២/០៧-១២-២០០៩-អ.វ.ត.ក/អ.ប.ជ ០៥ សាលដីកាលើពាក្យបណ្ដឹងតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុងរបស់ លោក អៀង សារី និង

លក្ខណៈជាចំណាត់ការរដ្ឋបាលបានឡើយ។ យើងត្រូវតម្រូវដោយច្បាប់ឱ្យផ្តល់សេចក្តីពិចារណាមួយដែលមានសំអាងហេតុត្រឹមត្រូវតាមផ្លូវតុលាការពាក់ព័ន្ធនឹងបញ្ហាចំពោះមុខ ដោយយោងទៅលើភារកិច្ចរបស់យើងក្នុងតួនាទីជាចៅក្រមស្របច្បាប់ និងជាចៅក្រមស្ថិតក្នុងតួនាទី។ យើងក៏បានដឹងអំពីការសច្ចាប្រណិធានចូលកាន់តំណែងរបស់យើងខ្ញុំ និងគោលការណ៍ក្រមសីលធម៌ចៅក្រម Bangalore[១៩] និងក្រមសីលធម៌ចៅក្រមនៅ អ.វ.ត.ក ដែលយើងត្រូវយកមកអនុវត្តផងដែរ នៅពេលយើងត្រូវបង្ហាញយោបល់ជំទាស់លើបញ្ហាមិនធម្មតាយ៉ាងដូច្នេះ។ ក្រៅពីជម្រើសនេះយើងគ្មានជម្រើសណាផ្សេងទៀតឡើយ។

១៦. ដោយហេតុថា វិធាន ៧២(៤)(ង) ចែងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះត្រូវមានសំអាងហេតុដើម្បីធានាតម្លាភាព យើងសូមភ្ជាប់មកជាមួយនឹងយោបល់ជំទាស់នេះនូវយោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ផុល និងចៅ ក្រម ហ្វូត វុទ្ធី ដូចដែលបានលើកនៅក្នុងអនុស្សរណៈ ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់ចៅក្រម ប្រាក់ គឹមសាន ផ្ញើទៅប្រធានការិយាល័យរដ្ឋបាល។

---

លោកស្រី អៀង ធីរិទ្ធ ប្តឹងជំទាស់ចៅក្រម Marcel Lemonde ឯកសារលេខ ៨ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ២០។ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៤៧&៤៨) សាលដីកាលើបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និង ដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ លើ ការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឯកសារលេខ D250/3/2/1/5 ចុះថ្ងៃទី២៧ ខែ មេសា ឆ្នាំ២០១០ កថាខណ្ឌ១៧។ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៤៣) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ D3/3/2/2 ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ កថាខណ្ឌ១៣-១៤។ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥៧) សាលាដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី សុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន ឯកសារលេខ D193/5/5 ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១០ កថាខណ្ឌ១៥-១៦។ ទម្រង់បែបបទលេខ ០០២/០៨-០៧-២០០៩-អ.វ.ត.ក-អ.ប.ជ, សាលដីកាលើបណ្តឹងជំទាស់របស់ជនត្រូវចោទទៅលើលោកបណ្ឌិត Stephen Heder និងលោកបណ្ឌិត David Boyle ឯកសារលេខ ៣ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ កថាខណ្ឌ ២០ និង ២២។

[19] *គោលការណ៍ក្រមសីលធម៌ចៅក្រម Bangalore* អនុម័តដោយក្រុមចៅក្រមទទួលបន្ទុកពង្រឹងសុច្ចរិតភាពចៅក្រម ធ្វើវិសោធនកម្មនៅកិច្ចប្រជុំតុមូលនៃប្រធានចៅក្រម ដែលប្រព្រឹត្តទៅនៅវិមានសន្តិភាព ទីក្រុងឡាអេ ថ្ងៃទី ២៥-២៦ ខែ វិច្ឆិកា ឆ្នាំ ២០០២។

១៧. យើងសូមលើកហេតុផលសម្រាប់យោបល់របស់យើងដូចខាងក្រោម ។

## ច្បាប់ជាធរមាន

១៨. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា មាត្រា ៣ កថាខណ្ឌ ៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣ ("កិច្ចព្រមព្រៀង")ចែងថា៖

"៣. ចៅក្រមត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលម្អៀង និងសុចរិត មានគុណសម្បត្តិ ដែលតម្រូវសម្រាប់តែងតាំងឱ្យបម្រើការក្នុងការិយាល័យតុលាការនៅប្រទេសរបស់ខ្លួន។ ចៅក្រមត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនអាចទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតឡើយ"។

១៩. មាត្រា៥(១) និង(៤) នៃកិច្ចព្រមព្រៀងចែងថា៖

"១. មានចៅក្រមស៊ើបអង្កេតខ្មែរមួយរូប និងចៅក្រមស៊ើបអង្កេតអន្តរជាតិមួយរូប ដែលបម្រើការជាសហចៅក្រមស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតទទួលខុសត្រូវចំពោះការងារស៊ើបអង្កេត"។

[...]

៤. សហចៅក្រមស៊ើបអង្កេតត្រូវសហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការស៊ើបអង្កេត។ នៅក្នុងករណីដែលចៅក្រមស៊ើបអង្កេតមិនអាចឯកភាពគ្នាថា ត្រូវបន្តការស៊ើបអង្កេតណាមួយ ការស៊ើបអង្កេតនោះត្រូវដំណើរការទៅមុខទៀត លើកលែងតែចៅក្រមទាំងនេះ ឬចៅក្រមណាម្នាក់ ក្នុងចំណោមចៅក្រមទាំងនេះ ធ្វើការស្នើសុំនៅក្នុងរយៈពេលសាមសិបថ្ងៃឱ្យដោះស្រាយការខ្វែងគំនិតគ្នានេះតាមមាត្រា៧"។

២០. មាត្រា ៧ នៃកិច្ចព្រមព្រៀងចែងទៀតថា៖

"១. ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញាបានធ្វើសំណើស្របតាមមាត្រា ៥ វាក្យខណ្ឌ៤ ឬមាត្រា៦ វាក្យខណ្ឌ៤ តាមករណីដែលកើតឡើង សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញាត្រូវធ្វើឯកសាររាយការណ៍ជាលាយលក្ខណ៍អក្សរពីអង្គហេតុ និងហេតុផលបញ្ជាក់ពីគោលជំហរខ្វែងគំនិតគ្នារបស់ខ្លួន ដាក់ជូនប្រធានការិយាល័យរដ្ឋបាល"។

២. ការខ្វែងគំនិតគ្នានេះនឹងត្រូវដោះស្រាយជាបន្ទាន់ដោយ "អង្គបុរេជំនុំជម្រះ" មួយមាន**ចៅក្រមប្រាំរូប** ដែលបីរូបតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយមានមួយរូបជាប្រធាន និងពីររូបទៀតតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តាមសំណើរបស់លោកអគ្គលេខាធិការ។ ការជ្រើសរើសចៅក្រមនេះត្រូវអនុវត្តតាមមាត្រា៣ វាក្យខណ្ឌទី៣។

៣. ពេលដែលទទួលបានឯកសាររាយការណ៍ដូចបានចែងក្នុងវាក្យខណ្ឌទី១ ប្រធានការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះភ្លាម និងបែងចែកឯការរាយការណ៍នេះជូនដល់សមាជិកអង្គបុរេជំនុំជម្រះ។

៤. ការសម្រេចសេចក្ដីរបស់អង្គបុរេជំនុំជម្រះដែលមិនអាចប្ដឹងឧទ្ធរណ៍បាន ត្រូវមានសំឡេងឆ្នោតគាំទ្រដោយចៅក្រមយ៉ាងតិចបួនរូប។ ការសម្រេចសេចក្ដីនេះត្រូវជូនដល់ប្រធានរដ្ឋបាលដែលនឹងផ្សព្វផ្សាយ ហើយចែកជូនដល់សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា។ សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញានឹងត្រូវដំណើរការភ្លាមៗ ស្របទៅតាមការសម្រេចរបស់អង្គបុរេជំនុំជម្រះ។ ប្រសិនបើគ្មានមតិភាគច្រើនដែលត្រូវការសម្រាប់ធ្វើការសម្រេចសេចក្ដីទេ ការស៊ើបអង្កេត ឬការចោទប្រកាន់នឹងត្រូវបន្តដំណើរការទៅមុខទៀត។ (គូសបញ្ជាក់បន្ថែម)"។

២១. មាត្រា ២៣ នៃច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក")[២០] ចែងថា៖

"រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជាបរទេស ដែលហៅថា "សហចៅក្រមស៊ើបអង្កេត" ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។

[20] ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃសម័យកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក")។

ក្នុងករណីដែលមានភាពមិនយល់ស្របគ្នារវាងសហចៅក្រម ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម៖

ការស៊ើបអង្កេតត្រូវធ្វើបន្ត ដរាបណាសហចៅក្រមស៊ើបអង្កេតទាំងពីរឬមួយរូប ក្នុងចំណោមពួកគេពុំបានប្តឹងមិនសុខចិត្តក្នុងរយៈពេលសាមសិបថ្ងៃ ភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយដោយអនុវត្តតាមបទប្បញ្ញត្តិដូចខាងក្រោម។

សហចៅក្រមស៊ើបអង្កេតត្រូវជូនកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីអង្គហេតុ និងហេតុផលទាំងឡាយ ចំពោះគោលជំហរខុសគ្នាដល់ប្រធានការិយាល័យរដ្ឋបាល។

ភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយភ្លាមដោយអង្គបុរេជំនុំជម្រះ ដូចមានចែងក្នុងមាត្រា ២០ នៃច្បាប់នេះ។

បន្ទាប់ពីទទួលបាននូវកំណត់ហេតុដូចមានចែងក្នុងកថាខណ្ឌទី៣ រួចមកប្រធានការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ ហើយជូនដំណឹងអំពីកំណត់ហេតុដល់សមាជិកអង្គបុរេជំនុំជម្រះ។

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំបើកផ្លូវឱ្យមានបណ្តឹងឧទ្ធរណ៍ តម្រូវឱ្យមានសំឡេងវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច។ សេចក្តីសម្រេចនេះត្រូវជូនដំណឹងដល់ប្រធានការិយាល័យរដ្ឋបាលដែលត្រូវផ្សព្វផ្សាយសេចក្តីសម្រេចនេះ ហើយជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតត្រូវចាត់ការបន្តជាបន្ទាន់ ដោយអនុវត្តតាមសេចក្តីម្រេចរបស់អង្គបុរេជំនុំជម្រះនេះ។ ប្រសិនបើពុំមានមតិភាគច្រើនដូចដែលតម្រូវឱ្យមានចំពោះសេចក្តីសម្រេចការស៊ើបអង្កេតត្រូវធ្វើបន្តទៀត"។

២២. មាត្រា២៦ នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ចែងថា៖

"សហចៅក្រមស៊ើបអង្កេតខ្មែរ និងចៅក្រមស៊ើបអង្កេតបម្រុងខ្មែរត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងចំណោមចៅក្រមវិជ្ជាជីវៈខ្មែរ។

*ចៅក្រមស៊ើបអង្កេតបម្រុងត្រូវជំនួសចៅក្រមស៊ើបអង្កេតពេញសិទ្ធិ នៅពេលណាដែលចៅក្រមនេះអវត្តមាន ឬមានធុរៈ។* ចៅក្រមស៊ើបអង្កេតទាំងនេះអាចបន្តបំពេញការងារប្រចាំថ្ងៃនៅក្នុងសាលាជម្រះក្តីដែលខ្លួនកំពុងបំពេញ។

ចៅក្រមស៊ើបអង្កេតបរទេសត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រាប់រយៈពេលនៃការស៊ើបអង្កេត បន្ទាប់ពីការជ្រើសរើសឱ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ។

អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវរៀបចំបញ្ជីបេក្ខជនយ៉ាងតិចពីររូបជាចៅក្រមស៊ើបអង្កេតបរទេសជូនរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងសហចៅក្រមស៊ើបអង្កេតពេញសិទ្ធិមួយរូប និងបម្រុងមួយរូបពីបញ្ជីបេក្ខជននេះ"។

២៣. មាត្រា ២៧ ថ្មី កថាខណ្ឌ ៣ នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ចែងថា៖

"ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតបរទេសណាមួយអវត្តមាន ឬមានធុរៈត្រូវជំនួសដោយចៅក្រមស៊ើបអង្កេតបម្រុងបរទេស"។

២៤. វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា[២១] ("វិធានផ្ទៃក្នុង") ចែងក្នុងវិធាន១៤ ថាពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត៖

"៤. វៀរលែងតែសកម្មភាពណា ដែលតម្រូវឱ្យអនុវត្តដោយរួមគ្នា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងវិធានផ្ទៃក្នុងនេះ សហចៅក្រមស៊ើបអង្កេតអាចផ្ទេរភារកិច្ចទៅឱ្យសហចៅក្រមស៊ើបអង្កេតណាមួយ ក្នុងចំណោមសហចៅក្រមស៊ើបអង្កេតទាំងពីរ តាមរយៈលិខិតរួមគ្នាជាលាយលក្ខណ៍អក្សរ ដើម្បីឱ្យបំពេញកិច្ចតែម្នាក់ឯងបាន។

៦. ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតបានអវត្តមាន កិច្ចដែលត្រូវបំពេញដោយផ្ទាល់ដោយសហចៅក្រមស៊ើបអង្កេតនោះដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ អាចអនុវត្តបានតាមមធ្យោបាយពីចម្ងាយ។

"៧. ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត នីតិវិធីដែលមានចែងក្នុងវិធាន ៧២ ត្រូវយកមកអនុវត្ត"។

២៥. "គោលការណ៍ជាសារវន្ត" ដូចមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុងតម្រូវថា៖

---

[21] វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិសោធនកម្មលើកទី៨ អនុម័តថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១១, "វិធានផ្ទៃក្នុង"។

"១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖

ក) ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ
ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។ នីតិវិធីត្រូវធានាឱ្យបាននូវភាពដាច់ដោយឡែកពីគ្នារវាងអាជ្ញាធរ ដែលទទួលបន្ទុកការចោទប្រកាន់ និងអាជ្ញាធរដែលទទួលបន្ទុកការវិនិច្ឆ័យទោស។

[...]

៤. ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប"។

២៦. វិធាន ៧២ នៃវិធានផ្ទៃក្នុងចែងថា៖

"១. ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតណាម្នាក់ ឬទាំងពីរអាចធ្វើកំណត់ហេតុអំពីមូលហេតុពិតប្រាកដនៃការខ្វែងយោបល់គ្នានេះ ដោយមានហត្ថលេខា និងចុះកាលបរិច្ឆេទ ដែលត្រូវយកទៅដាក់ចូលក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នាដោយឡែក ដែលរក្សាទុកដោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត។

២. ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ សហចៅក្រមស៊ើបអង្កេតណាម្នាក់អាចនាំយកករណីខ្វែងយោបល់គ្នានេះ ទៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយបញ្ជូនឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សរអំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នានេះទៅការិយាល័យរដ្ឋបាល ដែលត្រូវរៀបចំកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ និបញ្ជូនឯកសារទាំងនេះទៅចៅក្រមទាំងអស់ ដោយចម្លងជូនមួយច្បាប់ទៅសហចៅក្រមស៊ើបអង្កេតម្ខាងទៀត។ ប្រសិនបើការខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងការឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ រយៈពេលនេះត្រូវបន្ថយមកត្រឹម៥(ប្រាំ)ថ្ងៃ

វិញ។ ក្នុងករណីនេះ សហចៅក្រមស៊ើបអង្កេតម្ខាងទៀតអាចដាក់ជូនឯកសារឆ្លើយតបក្នុងរយៈពេល១០(ដប់)ថ្ងៃ។ ឯកសារអំណះអំណាងដែលទាក់ទងនឹងអង្គហេតុ និងមូលហេតុនៃការខ្វែងយោបល់គ្នាមិនត្រូវដាក់ចូលក្នុងសំណុំរឿងទេ លើកលែងតែក្នុងករណីដែលមានចែងក្នុងអនុវិធាន ៤(ខ) ខាងក្រោម។ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនសំណុំរឿងថតចម្លងមួយច្បាប់ទៅអង្គបុរេជំនុំជម្រះភ្លាម។

៣. ក្នុងអំឡុងពេលនៃការដោះស្រាយការខ្វែងយោបល់គ្នានេះ សហចៅក្រមស៊ើបអង្កេតត្រូវប្រឹងប្រែងស្វែងរកការឯកភាពគ្នា។ កិច្ច ឬសេចក្តីសម្រេចដែលជាកម្មវត្ថុនៃការខ្វែងយោបល់គ្នានេះត្រូវតែអនុវត្តលើកលែងតែបញ្ហាខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងចំណុចដូចខាងក្រោម៖

ក) សេចក្តីសម្រេចណាមួយដែលអាចនាំឲ្យជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីធ្វើបណ្តឹងឧទ្ធរណ៍ ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ។

ខ) ការជូនដំណឹងអំពីបទចោទប្រកាន់ ឬ

គ) ដីកាបង្គាប់ឱ្យចាប់ខ្លួន។

ក្នុងករណីទាំងនេះ គ្មានសកម្មភាពណាមួយដែលពាក់ព័ន្ធទៅការខ្វែងយោបល់គ្នា ត្រូវបានអនុវត្តទេ រហូតដល់មានការព្រមព្រៀងគ្នាណាមួយត្រូវបានបង្កើតឡើង ឬរយៈពេល៣០(សាមសិប)ថ្ងៃ បានកន្លងហួស ឬអង្គជំនុំជម្រះបានទទួលយករឿងខ្វែងយោបល់គ្នាមកជំនុំជម្រះ ហើយបានបញ្ចប់នីតិវិធីដោះស្រាយបញ្ហាខ្វែងយោបល់គ្នានេះ។

៤. អង្គបុរេជំនុំជម្រះត្រូវដោះស្រាយបញ្ហាខ្វែងយោបល់នេះ ដូចខាងក្រោម៖

ក) សវនាការរបស់អង្គបុរេជំនុំជម្រះត្រូវរៀបចំធ្វើឡើង និងប្រកាសសាលក្រមជាសម្ងាត់។

ខ) នៅពេលមានការខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងការសម្រេចសេចក្តី ដែលភាគីនៃសំណុំរឿងមានសិទ្ធិប្តឹងឧទ្ធរណ៍ទៅអង្គជំនុំជម្រះ តាមវិធានផ្ទៃក្នុងនេះត្រូវអនុវត្តដូចខាងក្រោម៖

(១) ក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះត្រូវជូនព័ត៌មានជាបន្ទាន់ទៅភាគីពាក់ព័ន្ធនឹងរឿងក្តីនិងមេធាវីរបស់ពួកគេអំពីថ្ងៃសវនាការ។

(២) សហព្រះរាជអាជ្ញា និងអ្នកតំណាងស្របច្បាប់របស់ភាគីដទៃទៀត ដែលពាក់ព័ន្ធអាចពិនិត្យមើលសំណុំរឿងនេះរហូតដល់ថ្ងៃសវនាការ។

(៣) សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីដទៃទៀតដែលពាក់ព័ន្ធ អាចដាក់សារណាជាលាយលក្ខណ៍អក្សរ ដូចមានចែងនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។ សារណានេះត្រូវដាក់បញ្ចូលភ្លាមទៅក្នុងសំណុំរឿងដោយក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះ។

(៤) ដោយផ្អែកតាមសំណើរបស់ចៅក្រមឬភាគីណាមួយ អង្គបុរេជំនុំជម្រះអាចសម្រេចថា ផ្នែកទាំងមូល ឬផ្នែកណាមួយនៃសវនការត្រូវធ្វើឡើងជាសាធារណៈ ជាពិសេសក្នុងករណី ដែលរឿងក្តីអាចត្រូវបញ្ចប់ដោយសេចក្តីសម្រេចរបស់ខ្លួន ដូចជាក្នុងករណីបណ្តឹងឧទ្ធរណ៍ ឬពាក្យស្នើសុំដែលពាក់ព័ន្ធនឹងយុត្តាធិការ ឬការរលត់បណ្តឹងអាជ្ញាប្រសិនបើអង្គបុរេជំនុំជម្រះយល់ឃើញថា សវនាការបែបនេះគឺធ្វើឡើងក្នុងប្រយោជន៍ដើម្បីយុត្តិធម៌ និងមិនប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ ឬវិធានការការពារណាមួយ ដែលអនុញ្ញាតដោយតុលាការ។

(៥) ក្នុងពេលសវនាការ សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីដទៃទៀតដែលពាក់ព័ន្ធអាចធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបបាន។.

គ) នៅក្នុងគ្រប់ករណីទាំងអស់ អង្គបុរេជំនុំជម្រះដោយអំណាចឆន្ទានុសិទ្ធិអាចបង្គាប់ឲ្យភាគីឬអ្នកជំនាញចូលមកបង្ហាញខ្លួនផ្ទាល់ រួមទាំងការបង្ហាញវត្ថុតាងផង។

ឃ) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឲ្យមានសំឡេងគាំទ្រពីចៅក្រម ៤ (បួន) រូប យ៉ាងតិច។ សេចក្តីសម្រេចនេះបិទផ្លូវប្តឹងឧទ្ធរណ៍។ ប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចរកបាននូវសំឡេងគាំទ្រភាគច្រើន តាមការតម្រូវស្របតាមមាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះ សេចក្តីសម្រេចដែលមិនមានសំឡេងគាំទ្រមានន័យថាដីកា ឬកិច្ចស៊ើបសួរដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតណាម្នាក់ត្រូវមានសុពលភាព ឬ មានន័យថាដីកា ឬកិច្ចស៊ើបសួរដែលបម្រុងនឹងធ្វើដោយសហចៅក្រមស៊ើបអង្កេតម្នាក់ត្រូវតែយកមកអនុវត្ត។ ប៉ុន្តែនៅពេលការខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងការឃុំខ្លួន

បណ្តោះអាសន្ន ហើយបើអង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រតាមការតម្រូវបានទេ នោះជនត្រូវចោទត្រូវសន្មតថាមានសេរីភាព។

ង) រាល់សេចក្តីសម្រេចទាំងអស់ដែលមានចែងក្នុងវិធាននេះ រួមទាំងគំនិតជំទាស់ផងត្រូវមានបញ្ជាក់ពីមូលហេតុ និងចុះហត្ថលេខាដោយសាម៉ីខ្លួន។ ក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះត្រូវបញ្ជូនសេចក្តីសម្រេចនេះ ទៅប្រធានការិយាល័យរដ្ឋបាលដែលត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត។ លើសពីនេះសេចក្តីសម្រេចដែលពាក់ព័ន្ធទៅនឹងករណីដូចមានក្នុងអនុវិធាន ៤(ខ) ត្រូវជូនដំណឹងទៅភាគី។ សហចៅក្រមស៊ើបអង្កេតត្រូវដាក់បញ្ចូលសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅក្នុងសំណុំរឿង និងត្រូវបន្តកិច្ចដំណើរការនីតិវិធីជាបន្ទាន់ស្របតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ”។

២៧. យើងសូមយោងទៅលើឯកសារ “លក្ខខណ្ឌនៃការផ្តល់សេវាកម្ម-ចៅក្រមពីភាគីអន្តរជាតិ” ចុះថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១០ ដែលនៅលើទំព័រទីមួយមានខ្លឹមសារនៃការធ្វើសច្ចាប្រណិធានរបស់ ចៅក្រមថា៖

“៣. ចៅក្រមតម្រូវឱ្យធ្វើសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរដូចខាងក្រោម ដោយមានអគ្គលេខាអង្គការសហប្រជាជាតិ ឬអ្នកតំណាងដែលទទួលបានការអនុញ្ញាតរបស់លោកធ្វើជាសាក្សី៖

ខ្ញុំសូមប្រកាសជាឱឡារិកថាខ្ញុំនឹងបំពេញតួនាទី និងប្រើប្រាស់អំណាចជាសហចៅក្រមស៊ើបអង្កេត នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដោយថ្លៃថ្នូរ ស្មោះត្រង់មិនលម្អៀង និងដោយមានសតិ សម្បជញ្ញៈ ហើយខ្ញុំនឹងមិនស្វែងរក ឬទទួលបង្គាប់បញ្ជានៅក្នុងការអនុវត្តតួនាទីទាំងនោះ ឬការ ប្រើប្រាស់អំណាចទាំងនោះពីរដ្ឋាភិបាល ឬពីប្រភពណាមួយផ្សេងទេ”។

## ភាពទទួលយកបាននៃការខ្វែងយោបល់គ្នា

### ១. ភាពទទួលយកបានជាផ្លូវការ

២៨. វិធាន ៧២ នៃវិធានផ្ទៃក្នុងជាវិធានត្រូវអនុវត្តផ្នែកនីតិវិធីក្នុងការដោះស្រាយការខ្វែងយោបល់គ្នា

រវាងសហចៅក្រមទាំងពីរ។ វិធាន៧២(២) ចែងថា "ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ សហចៅក្រមស៊ើបអង្កេតណាម្នាក់អាចនាំយកករណីខ្វែងយោបល់គ្នានេះ ទៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយបញ្ជូនឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សរអំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នានេះទៅការិយាល័យរដ្ឋបាល ដែលត្រូវរៀបចំកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ និងបញ្ជូនឯកសារទាំងនេះ ទៅចៅក្រមទាំងអស់ ដោយចម្លងជូនមួយច្បាប់ទៅសហចៅក្រមស៊ើបអង្កេតម្ខាងទៀត"[២២]។

២៩. ថ្វីបើនៅក្នុងកំណត់ហេតុនៃការខ្វែងយោបល់គ្នា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំបានបញ្ជាក់ថាតើការខ្វែងយោបល់គ្នានេះបានកើតមានចាប់តាំងពីពេលណាក៏ដោយ ក៏តាមរយៈឯកសារនៅចំពោះមុខអង្គជំនុំជម្រះហាក់បង្ហាញថា សហចៅក្រមស៊ើបអង្កេតជាតិ បានបង្ហាញការជំទាស់របស់ខ្លួនទៅនឹងទង្វើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ក្នុងលិខិតមួយ ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១១[២៣]។

៣០. កំណត់ហេតុនៃការខ្វែងយោបល់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ និងត្រូវបានការិយាល័យរដ្ឋបាលជូនដំណឹង ទៅអង្គបុរេជំនុំជម្រះ ដោយចម្លងជូនសហចៅក្រមស៊ើបអង្កេតជាតិ នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១។ កំណត់ហេតុនៃការខ្វែងយោបល់គ្នាត្រូវបានដាក់មកអង្គបុរេជំនុំជម្រះក្នុងរយៈពេលកំណត់ចំនួន ៣០ថ្ងៃ ដូចមានចែងក្នុងកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក និងវិធានផ្ទៃក្នុង។ ហេតុដូច្នេះ កំណត់ហេតុនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់គតិយុត្តិ ដែលអាចឲ្យយើងអាចទទួលយកបាន។

## ២. គុណវុឌ្ឍិ

៣១. យើងសូមជំទាស់ទៅនឹងយោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី ត្រង់ចំណុចដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង "ពុំទាន់មានគុណសម្បត្តិ

---

[22] វិធាន៧២(២) (វិសោធនកម្មទី៨)។

[23] កំណត់ហេតុនៃការខ្វែងយោបល់គ្នា ។

គ្រប់គ្រាន់ [គុណវុឌ្ឍិ] ក្នុងការបំពេញតួនាទីតាមនីតិវិធីច្បាប់ជាធរមាន"[២៤]។ ដោយកត់សម្គាល់ឃើញថា ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ផុល និងចៅក្រម ហួត វុទ្ធី ពុំបានផ្តល់សេចក្តីពន្យល់ ឬសំអាងហេតុណាមួយសម្រាប់គាំទ្រយោបល់របស់ពួកគាត់ យើងសូមបដិសេធមិនទទួលស្គាល់សេចក្តីសន្និដ្ឋានរបស់ពួកគាត់នោះទេ។

៣២. ចៅក្រម Laurent Kasper-Ansermet បានដាក់កំណត់ហេតុស្តីពីការខ្វែងយោបល់នេះមកអង្គបុរេជំនុំជម្រះ ក្រោមកាលៈទេសៈដូចខាងក្រោម៖

៣៣. អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Siengried Blunk បានដាក់លិខិតសុំលាលែងរបស់ខ្លួនកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១។ នីតិវិធីសម្រាប់*ការតែងតាំងនៃ*សហចៅក្រមស៊ើបអង្កេតអន្តរជាតិ*ថ្មី* កំពុងដំណើរការ[២៥]។ យើងយល់ថា នីតិវិធីនេះពុំពាក់ព័ន្ធឡើយទៅនឹងគុណវុឌ្ឍិរបស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ Kasper-Ansermet ដើម្បីចូលជំនួសតំណែងចៅក្រម Blunk ជាបណ្តោះអាសន្ន ក្នុងឋានៈជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងនោះ។ ក្រោយពេលអវត្តមានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពេញសិទ្ធិ ហើយ*ក្នុងពេលទន្ទឹមនឹងនេះ* អនុលោមតាមច្បាប់ជាធរមាននៅអ.វ.ត.ក[២៦] ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីតុលាការបន្តប្រព្រឹត្តដោយរលូន និងទាន់ពេលវេលា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងត្រូវបំពេញភារកិច្ចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

៣៤. មាត្រា ២៦ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មានភាពច្បាស់លាស់ ដោយហេតុថា មាត្រានេះចែងថា នៅពេលដែលសហចៅក្រមស៊ើបអង្កេតអវត្តមាន រួមទាំងនៅក្នុងករណីដែលចៅក្រម

---

[24] អនុស្សរណៈផ្ញើជូនប្រធានការិយាល័យរដ្ឋបាលស្តីទី ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ ២០១២ ផ្ញើជូនដោយ ចៅក្រម ប្រាក់ គឹមសាន ចុះហត្ថលេខាក្នុងសមត្ថភាពលោកជាប្រធាននៃអង្គបុរេជំនុំជម្រះ ក្រោមកម្មវត្ថុ "បញ្ជូនត្រឡប់វិញនូវសំណុំឯកសារដែលការិយាល័យរដ្ឋបាលផ្ញើជូនអង្គបុរេជំនុំជម្រះ" ("អនុស្សរណៈពីចៅក្រម ប្រាក់ គឹមសាន")។

[25] នីតិវិធីសម្រាប់ការតែងតាំងមុខតំណែងទំនេរ មានចែងក្នុងមាត្រា៥(៦) នៃកិច្ចព្រមព្រៀង មាត្រា៤៦ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាន៧ (៤) នៃវិធានផ្ទៃក្នុង ដែលជាឯកសារយោងសម្រាប់បទប្បញ្ញត្តិផ្សេងៗទៀតនៃច្បាប់ជាធរមាន។

[26] មាត្រា២៦នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ចែងថា "ចៅក្រមស៊ើបអង្កេតបម្រុងត្រូវជំនួសចៅក្រមស៊ើបអង្កេតពេញសិទ្ធិនៅពេលណាដែលចៅក្រមនេះអវត្តមាន ឬមានធុរៈ" ។

លាឈប់ពីតួនាទី សហចៅក្រមស៊ើបអង្កេតបម្រុងអាចបន្តបំពេញការងារប្រចាំថ្ងៃរបស់សហចៅក្រមស៊ើបអង្កេត ដែលអវត្តមាននោះ។ អនុលោមតាមមាត្រានេះ លក្ខខណ្ឌត្រូវបំពេញសម្រាប់ឱ្យចៅក្រមបម្រុងមកចូលជំនួសតំណែងសហចៅក្រមស៊ើបអង្កេតពេញសិទ្ធិ នៅ អ.វ.ត.ក រួមមាន៖

១) *អវត្តមាន* (ដែលរួមបញ្ចូលទាំងអវត្តមានដោយសារការលាឈប់ពីតំណែង) របស់សហចៅក្រមស៊ើបអង្កេតដែលធ្លាប់បានទទួលការតែងតាំង

២) ចៅក្រមជំនួសត្រូវតែ*បានតែងតាំងជា*សហចៅក្រមស៊ើបអង្កេត*បម្រុង*។

មិនដូចទៅនឹងករណីពាក់ព័ន្ធនឹងចៅក្រមបម្រុងរបស់អង្គជំនុំជម្រះ[២៧] ឬចៅក្រមស៊ើបអង្កេតដែលបំពេញការងារនៅតុលាការកម្ពុជាធម្មតា[២៨] សម្រាប់ករណីពាក់ព័ន្ធនឹងសហ

---

[27] ក្នុងករណីអវត្តមានរបស់ចៅក្រមនៃអង្គជំនុំជម្រះនៅ អ.វ.ត.ក ថ្វីបើមាត្រា ១១(២) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា៖ "ចៅក្រមបម្រុងខ្មែរត្រូវជំនួសចៅក្រមជម្រះក្តីខ្មែរពេញសិទ្ធិ នៅពេលដែលចៅក្រមនេះអវត្តមាន ឬមានធុរៈ" ក៏ដោយ ក៏វិធាន ១៧(២) នៃវិធានផ្ទៃក្នុងបានយោងទៅដល់វិធាន ៧៧ ៧៩ និង ១០៨ ដែលបានតម្រូវយ៉ាងច្បាស់*ឱ្យមានការតែងតាំងពីប្រធានអង្គជំនុំជម្រះ* ដើម្បីឱ្យការជំនួសនោះមានសុពលភាព។ លើសពីនេះ យើងក៏កត់សម្គាល់ផងដែរថា ការជំនួសតួនាទីនៅអង្គជំនុំជម្រះមានន័យច្បាស់ថា ក្នុងអំឡុងពេលនៃការជំនួសដែលមានសុពលភាព ចៅក្រមបម្រុងមានសិទ្ធិអំណាច "សម្តែងយោបល់" និង "សម្រេច" (ជាក់ស្តែង សូមមើលវិធាន ៧៧(៧)) ថ្វីត្បិតមាត្រា ២៦ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ពុំមានបញ្ជាក់ ឬដាក់កំហិតឱ្យបានជាក់លាក់ទៅលើអំណាចរបស់ចៅក្រមជំនួស ក្នុងអំឡុងរយៈពេលនៃការជំនួសដែលមានសុពលភាពនោះ។

[28] មាត្រា ៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា៖ "កាលណាចៅក្រមស៊ើបសួរណាម្នាក់ ពុំអាចបំពេញមុខងាររបស់ខ្លួនបានទេ ដោយសារការឈប់សម្រាក ដោយមានជំងឺ ឬដោយសារមូលហេតុដទៃផ្សេងទៀត ចៅក្រមស៊ើបសួរផ្សេងទៀតនៃតុលាការដដែល*ត្រូវបានចាត់តាំងជាបណ្តោះអាសន្ន ដោយប្រធានតុលាការ* ដើម្បីបំពេញមុខងារស៊ើបសួរ។ ក្នុងករណីពុំមានចៅក្រមស៊ើបសួរទេ ចៅក្រមផ្សេងទៀតនៃតុលាការដដែលអាចត្រូវបានចាត់តាំងជាបណ្តោះអាសន្ន ដោយ*ប្រធានតុលាការ*ដើម្បីបំពេញមុខងារស៊ើបសួរ។ *ប្រធានតុលាការ*ចេញដីកាចាត់តាំងមួយដែលពុំបើកផ្លូវតវ៉ាឡើយ"។ ដោយសារ អ.វ.ត.ក ជាតុលាការពិសេសដែលច្បាប់បង្កើតតុលាការនេះពុំបានចែងអំពីអត្ថិភាពនៃ "ប្រធានតុលាការ" ឡើយ (ដែលមិនដូចទៅនឹងតួនាទីរបស់ប្រធានអង្គជំនុំជម្រះណាមួយ ឬប្រធានកិច្ចប្រជុំពេញអង្គ) និងដែលពុំមាន "ចៅក្រមស៊ើបអង្កេតដទៃទៀត" ប៉ុន្តែមាន "ចៅក្រមស៊ើបអង្កេតបម្រុង" ទើបច្បាប់ជាធរមានចែងថា "នៅពេលអវត្តមានសហចៅក្រមស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតបម្រុងត្រូវឡើងជំនួស" និងពុំចាំបាច់តម្រូវជាចាំបាច់ឱ្យមានការតែងតាំងពីសំណាក់ប្រធានតុលាការឡើយ។ ដោយអនុលោមតាមច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នៅក្នុងបរិបទនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ការតែងតាំងសហចៅក្រមស៊ើបអង្កេតបម្រុងអាចត្រូវបានចាត់ទុកជា "ការតែងតាំងជាមុន"។ ក្នុងបរិបទ អ.វ.ត.ក ដែលជាតុលាការពិសេស ចំណុចខាងលើមានភាពសមហេតុផលទាំងស្រុង និង

ចៅក្រមស៊ើបអង្កេតបម្រុងនៅ អ.វ.ត.ក ច្បាប់ជាធរមានពុំមានចែងអំពីលក្ខខណ្ឌណាមួយផ្សេង ឬតម្រូវឱ្យមាននីតិវិធីណាមួយផ្សេង ដូចជា "ការចាត់តាំង" ឬ "ការតែងតាំង" សហចៅក្រមស៊ើបអង្កេតបម្រុងឱ្យចូលជំនួសបណ្ដោះអាសន្ននូវតួនាទីរបស់សហចៅក្រមស៊ើបអង្កេតដែលអវត្តមានពី "ប្រធានតុលាការ" ឡើយ (ដែលខុសពីការតែងតាំងបំពេញតំណែងទំនេរ)[២៩]។

៣៥. មិនថាចៅក្រមស៊ើបអង្កេតអន្តរជាតិ Blunk មានហេតុផលអ្វីចំពោះការអវត្តមានរបស់គាត់នោះទេ យើងមិនអាចប្រកែកបានឡើយថា ចៅក្រមពេញសិទ្ធិរូបនេះ ពុំមានវត្តមាន តាមរយៈការដាក់ពាក្យលាឈប់ពីតួនាទីរបស់គាត់។ ហេតុដូច្នេះ លក្ខខណ្ឌទីមួយដើម្បីឱ្យមាត្រា ២៦ នៃច្បាប់ស្ដីអំពី អ.វ.ត.ក មានអានុភាពត្រូវបានបំពេញ។

៣៦. ចំណុចទីពីរ ជាការដែលមិនអាចប្រកែកបានឡើយថា ចៅក្រម Kasper-Ansermet ធ្លាប់ត្រូវបានតែងតាំងជាផ្លូវការ និងបានធ្វើសម្បថក្នុងឋានៈជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង[៣០]។ នេះជាបញ្ហាពាក់ព័ន្ធនឹងកំណត់ហេតុសាធារណៈ។ ហេតុដូច្នេះ លក្ខខណ្ឌទីពីរសម្រាប់ឱ្យមាត្រា ២៦ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក មានអានុភាពក៏ត្រូវបានបំពេញទៀត។

៣៧. នៅពេលលក្ខខណ្ឌទាំងពីរខាងលើត្រូវបានបំពេញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet មានសិទ្ធិអំណាចអនុវត្តតួនាទីជាអ្នកជំនួសតំណែងបណ្ដោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Blunk ដែលអវត្តមានរហូតដល់ពេលចៅក្រម Kasper-Ansermet បានទទួលការតែងតាំងត្រឹមត្រូវតាមច្បាប់ឱ្យចូលជំនួសចៅក្រម Blunk ជាអចិន្ត្រៃយ៍ ក្នុងឋានៈជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ ប្រសិនបើចៅក្រមបម្រុងមិនអាចចូលជំនួសបណ្ដោះអាសន្ននូវតំណែងរបស់ចៅក្រម ដែលអវត្តមានដោយត្រូវរង់ចាំការចូលជំនួសតំណែងជាអចិន្ត្រៃយ៍ ពេល

---

ដោយហេតុថា ការិយាល័យសហចៅក្រមស៊ើបអង្កេត ឬ អ.វ.ត.ក ពុំមាន "ប្រធានការិយាល័យ" ឬ "ប្រធានតុលាការ" ដើម្បី "ចាត់តាំង" ឬ "តែងតាំង" ចៅក្រមបម្រុង។

[29] ស្រដៀងគ្នានេះ សូមមើលផងដែរ កថាខណ្ឌទី ២ នៃមាត្រា ១៨ ថ្មីនៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក។

[30] សន្លឹកកថាបើកកិច្ចប្រជុំពេញអង្គជាសាធារណៈរបស់ប្រធាន គង់ ស្រីម នៅក្នុងកិច្ចប្រជុំពេញអង្គ អ.វ.ត.ក ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០១១។

នោះយើងអាចជជីកសួរ ដោយសមហេតុផលអំពីគោលបំណងនៃការបង្កើតឱ្យមានតំណែងចៅក្រមស៊ើបអង្កេតបម្រុង។

៣៨. ហេតុដូច្នេះ យើងយល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet មានសិទ្ធិដាក់កំណត់ហេតុស្តីពីការខ្វែងយោបល់នេះមកអង្គបុរេជំនុំជម្រះ ដោយអនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង។

៣៩. តាមសំអាងហេតុដូចដែលបានបញ្ជាក់ខាងលើ យើងយល់ថា កំណត់ហេតុស្តីពីការខ្វែងយោបល់មានលក្ខណៈអាចឱ្យយើងទទួលយកបាន ហើយនៅពេលដែលបញ្ហាស្ថិតក្នុងស្ថានភាពបែបនេះ យើងគប្បីបន្តបញ្ចេញយោបល់របស់យើងពាក់ព័ន្ធនឹងការដោះស្រាយបញ្ហាខ្វែងយោបល់នេះ ដោយហេតុថា ច្បាប់តម្រូវឱ្យយើងធ្វើដូច្នេះ។

## បទដ្ឋាននៃការពិនិត្យមើលឡើងវិញទៅលើការខ្វែងយោបល់គ្នា

៤០. នៅក្នុងការពិចារណារបស់ខ្លួនចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា[៣១] ("ការពិចារណាទៅលើការខ្វែងយោបល់គ្នាលើកដំបូង") អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា៖

> "កិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុងពុំមានចែងច្បាស់ថាតើអង្គបុរេជំនុំជម្រះត្រូវដោះស្រាយដូចម្តេចឡើយ លើការខ្វែងយោបល់គ្នា [....] តួនាទីរបស់អង្គជំនុំជម្រះនៅលើបញ្ហានេះមានលក្ខណៈពិសេស ដោយពុំមានតុលាការពិសេសណាផ្សេងទៀតមានភារកិច្ចដោះស្រាយវិវាទឡើយ [..]"[៣២] ។

> "ដោយអនុលោមតាមមាត្រា ៦ នៃកិច្ចព្រមព្រៀង តួនាទីរបស់អង្គបុរេជំនុំជម្រះនៅដំណាក់កាលនេះគឺត្រូវ "ដោះស្រាយបញ្ហាខ្វែងយោបល់" រវាង [បុគ្គលទាំងឡាយណា] ដែល "ពុំមានលទ្ធភាពឯកភាពគ្នាទៅបញ្ហាណាមួយ [....]។ សម្រាប់គោលបំណងនេះ [ពួកគេ] ត្រូវ

---

[31] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងការខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន៧១ នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ ("សេចក្តីពិចារណាទៅលើការខ្វែងយោបល់លើកដំបូង")។

[32] សេចក្តីពិចារណាលើការខ្វែងយោបល់លើកដំបូង, កថាខណ្ឌ ២០។

"ធ្វើកំណត់ហេតុស្តីពីចំណុចជាក់ស្តែងនៃការខ្វែងយោបល់ នៅលើឯកសារដែលមានហត្ថលេខា និងកាលបរិច្ឆេទ។ កំណត់ហេតុនេះនឹងត្រូវចុះក្នុងបញ្ជីនៃការខ្វែងយោបល់ដោយមានក្រឡាបញ្ជីជាអ្នករក្សាទុក[...]"។ វិធានផ្ទៃក្នុង [...]បញ្ជាក់ទៀតថា [បុគ្គលណា] ដែលសម្រេចជូនដំណឹងមកអង្គបុរេជំនុំជម្រះត្រូវដាក់ "សេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សរអំពីអង្គហេតុ និងសំអាងហេតុស្តីពីការខ្វែងយោបល់"[៣៣] មកអង្គបុរេជំនុំជម្រះ។

"យោងតាមបញ្ញត្តិទាំងនេះ អង្គបុរេជំនុំជម្រះយល់ថា *វិសាលភាពនៃការពិនិត្យមើលឡើងវិញ របស់ខ្លួនកំហិតត្រឹមតែជាការដោះស្រាយបញ្ហាមួយចំនួន ដែល [សហចៅក្រមស៊ើបអង្កេត] មិនឯកភាពគ្នាប៉ុណ្ណោះ។* ក្នុងន័យនេះ អង្គបុរេជំនុំជម្រះនឹងពិចារណាតែទៅលើអង្គហេតុ និងសំអាងហេតុណាដែលបានលើកឡើងចំពោះមុខខ្លួនប៉ុណ្ណោះ [...]។ ដោយអនុលោមតាមវិធានផ្ទៃក្នុង [...] អង្គហេតុ និងសំអាងហេតុត្រូវលើកនៅក្នុងសេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សរ [...] និងចម្លើយតប [...]។ បន្ថែមពីលើព័ត៌មានដែលពួកគេបានផ្តល់នៅក្នុងសារណាអស់ទាំងនេះ អង្គបុរេជំនុំជម្រះ [អាច] ស្នើឱ្យ [សហចៅក្រមស៊ើបអង្កេត] ផ្តល់ការបញ្ជាក់បំភ្លឺបន្ថែមលើការខ្វែងយោបល់ [....]។ ក្នុងកាលៈទេសៈបែបនេះ អង្គបុរេជំនុំជម្រះនឹងពិចារណាផងដែរទៅលើអង្គហេតុ និងសំអាងហេតុដែលបានលើកនៅក្នុងចម្លើយតប និងសារណាតប [ដទៃទៀត] [...]"[៣៤]។

## ការពិនិត្យមើលឡើងវិញទៅលើអង្គសេចក្តី

៤១. ការខ្វែងយោបល់គ្នាបានកើតមាន ពាក់ព័ន្ធទៅនឹងលទ្ធភាពរបស់អង្គបុរេជំនុំជម្រះក្នុងការទទួលយកដីកាចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១១ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet បានស្នើសុំបន្តកិច្ចស៊ើបសួរលើសំណុំរឿង០០៣ ("ដីកាដែលត្រូវបានស្នើឡើង")។ បន្ទាប់ពីបានយល់ថា ដីកាដែលត្រូវបានស្នើឡើងនោះ ពាក់ព័ន្ធនឹងខ្លឹមសារនៃកិច្ចដំណើរការនីតិវិធី សហចៅក្រមស៊ើបអង្កេតជាតិបានគូសបញ្ជាក់ថា ខ្លួនបដិសេធមិន "ពិភាក្សាអំពីខ្លឹមសារនៃកិច្ចដំ

[33] សេចក្តីពិចារណាលើការខ្វែងយោបល់លើកដំបូង, កថាខណ្ឌ ២៣។

[34] សេចក្តីពិចារណាលើការខ្វែងយោមល់លើកដំបូង, កថាខណ្ឌ ២៤។

ណើរការនីតិវិធី” ជាមួយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet ល្គឹកណាតែចៅក្រមបម្រុងរូបនេះ “បានទទួលការតែងតាំងជាផ្លូវការពីសំណាក់ឧត្តមក្រុមប្រឹក្សាអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជា ជាមុនសិន”[៣៥]។ ដូចដែលបានពន្យល់ពីខាងលើ សហចៅក្រមស៊ើបអង្កេតជាតិពុំដាក់ចម្លើយតបណាមួយផ្សេងទៀតជាផ្លូវការ ដែលមានពន្យល់អំពីហេតុផលនៃការជំទាស់របស់ខ្លួនឡើយ។ ថ្វីបើដូច្នេះក្តី ក៏អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង និងសហចៅក្រមស៊ើបអង្កេតជាតិបានចេញសេចក្តីប្រកាសព័ត៌មានឆ្លើយឆ្លងគ្នា។ ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១១ សេចក្តីប្រកាសព័ត៌មានទាំងពីរបានចុះផ្សាយលើគេហទំព័រ អ.វ.ត.ក ដែលយើងបានដកស្រង់ខ្លឹមសារទាំងស្រុងនៅក្នុងកថាខណ្ឌ ៨ និងកថាខណ្ឌ ៩ ខាងលើនៅក្នុងឯកសារស្តីពីយោបល់របស់យើងនេះ។

៤២. ថ្វីត្បិតយើងឯកភាពតាមគំនិតរបស់ចៅក្រម យូ ប៊ុនឡេង ដែលថា បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Siegfried BLUNK បានលាឈប់ពីតួនាទី នៅពុំទាន់មានការតែងតាំងសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មីជាផ្លូវការក៏ដោយ ក៏យើងកត់សម្គាល់ឃើញថា ចៅក្រម យូ ប៊ុនឡេង បានភ័ន្តច្រឡំលើអង្គហេតុ និងអង្គច្បាប់ដោយពុំបានយល់អំពីសិទ្ធិអំណាចរបស់សហចៅក្រមស៊ើបអង្កេតបម្រុងក្នុងការ *បំពេញតួនាទីបណ្តោះអាសន្នជំនួសឱ្យ* សហចៅក្រមស៊ើបអង្កេតដែលអវត្តមាន រហូតដល់ពេលមានការតែងតាំងចៅក្រមបម្រុងឱ្យចូលជំនួសតំណែងរបស់ចៅក្រម Blunk ជាអចិន្ត្រៃយ៍ ។

៤៣. ជាបឋមថ្វីបើចៅក្រម យូ ប៊ុនឡេង លើកឡើងអំពី “ទម្លាប់អនុវត្តន៍ទូទៅដែលត្រូវបានអនុវត្តមកទល់នឹងពេលបច្ចុប្បន្ន” ក៏ដោយ ក៏យើងសង្កេតឃើញថា យើងពុំបានប្រទះឃើញឧទាហរណ៍ណាមួយទាល់តែសោះដែលបង្ហាញអំពីអត្ថិភាព (ឬផ្ទុយពីនេះ) នៃទម្លាប់អនុវត្តន៍ជាធរមាននោះនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក នៅពេលសហចៅក្រមស៊ើបអង្កេតបម្រុងដែលបានទទួលការតែងតាំងត្រឹមត្រូវ ពុំអាចចូលជំនួសបណ្តោះអាសន្ននូវតំណែងរបស់សហចៅក្រមស៊ើបអង្កេត ដែលអវត្តមាន ដោយពុំចាំបាច់រង់ចាំ “ការតែងតាំងជាផ្លូវការ” ជាមុនសិន។

[35] អនុស្សរណៈផ្ទៃក្នុង ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១១ របស់ចៅក្រម យូ ប៊ុនឡេង ផ្ញើទៅចៅក្រម Kasper-Anserment។

៤៤. ចំណុចទីពីរ ថ្វីត្បិតចៅក្រម យូ ប៊ុនឡេង យោងទៅលើបញ្ញត្តិគតិយុត្តិ ដែលអាចយកមកអនុវត្តបាន នៅក្នុងពេលតំណែងរបស់សហចៅក្រមស៊ើបអង្កេត ដែលបានលាឈប់ពីតួនាទីស្ថិតនៅទំនេរក៏ដោយ ក៏ចៅក្រម យូ ប៊ុនឡេង ពុំបានបែងចែកឱ្យច្បាស់រវាងបញ្ញត្តិគតិយុត្តិសម្រាប់ការចូលជំនួសជាអចិន្ត្រៃយ៍តាមការតែងតាំងថ្មី និងបញ្ញត្តិគតិយុត្តិដែលអាចយកមកអនុវត្តបានសម្រាប់គោលបំណងនៃការចូលជំនួស *ជាបណ្ដោះអាសន្ន* នូវតំណែងរបស់សហចៅក្រមស៊ើបអង្កេតដែលអវត្តមាន។ បញ្ញត្តិនោះចែងច្បាស់ថា "ចៅក្រមស៊ើបអង្កេតបម្រុងត្រូវជំនួសចៅក្រមស៊ើបអង្កេតពេញសិទ្ធិ នៅពេលណាដែលចៅក្រមពេញសិទ្ធិអវត្តមាន"[៣៦] និងពុំត្រូវការនីតិវិធីបន្ថែមណាមួយសម្រាប់ការចូលជំនួសតំណែងនេះឡើយ[៣៧]។ បញ្ញត្តិទាំងនេះមានចែងនៅក្នុងច្បាប់ ប្រយោជន៍ដើម្បីធានាថា អវត្តមានរបស់ចៅក្រមណាម្នាក់នឹងពិតជាពុំប៉ះពាល់ ឬអូសបន្លាយកិច្ចដំណើរការនីតិវិធីឡើយ។ អត្ថិភាពនៃតួនាទីរបស់ចៅក្រមបម្រុងគឺដើម្បីការពារគោលបំណងនេះឯង។

៤៥. ហេតុដូច្នេះ យើងយល់ថា សហចៅក្រមស៊ើបអង្កេតជាតិបានភ័ន្តច្រឡំ នៅពេលខ្លួនបានបដិសេធមិនព្រមពិនិត្យមើលឡើងវិញនូវលទ្ធភាពរបស់ខ្លួន ក្នុងការទទួលយកដីកាដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានស្នើ។ យើងយល់ថា ទង្វើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងដែលកំពុងជំនួស និងបំពេញតួនាទី *ជាបណ្ដោះអាសន្ន* របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលអវត្តមាន គឺជាទង្វើដែលមានសុពលភាពគតិយុត្តិ រហូតដល់ពេលមានការតែងតាំងសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី ដើម្បីចូលជំនួស*ជាអចិន្ត្រៃយ៍* នូវតំណែងរបស់អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានលាឈប់ពីតួនាទីកាលពីថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១។

៤៦. លើសពីនេះទៀត តាមយុត្តិសាស្ត្រកន្លងមករបស់អង្គបុរេជំនុំជម្រះ និងតាមការបញ្ជាក់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងនៅក្នុងដីកាដែលខ្លួនបានស្នើ[៣៨] យើងយល់ថា សហចៅក្រមស៊ើបអង្កេតអាចធ្វើការពិចារណាឡើងវិញទៅលើសេចក្ដីសម្រេចរបស់ខ្លួន នាពេលកន្លងមក។ តាមយុត្តិសាស្ត្ររបស់ខ្លួននាពេលកន្លងមក អង្គបុរេជំនុំជម្រះបានអនុវត្តលក្ខខណ្ឌដូចខាងក្រោមសម្រាប់

---

[36] ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក, មាត្រា ២៦។

[37] សូមមើលផងដែរមាត្រា ២៧ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ដែលចែងស្រដៀងគ្នា។

[38] ដីកាដែលត្រូវបានស្នើឡើង, កថាខណ្ឌ ៤។

ការពិចារណាឡើងវិញ៖

"២៥. ពាក្យសុំពិចារណាសារជាថ្មីអាចទទួលយកបាន ប្រសិនបើមានមូលដ្ឋានស្របច្បាប់ដាក់ជូនអង្គបុរេជំនុំជម្រះដើម្បីឱ្យធ្វើការពិចារណាសេចក្តីសម្រេចរបស់ខ្លួនកាលពីពេលមុន។ អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី បានសម្រេចថា អង្គជំនុំជម្រះជាដរាបអាច "ពិចារណាឡើងវិញទៅលើសេចក្តីសម្រេចដែលខ្លួនបានចេញកាលពីពេលមុន ប៉ុន្តែការពិចារណាឡើងវិញនេះមិនមែនដោយសារ*កាលៈទេសៈមានការប្រែប្រួល* ប៉ុណ្ណោះនោះទេ គឺអាចដោយសារនៅពេលដែលខ្លួនយល់ឃើញថា សេចក្តីសម្រេចមុនរបស់ខ្លួនមានកំហុស ឬបណ្តាលឱ្យមានភាពអយុត្តិធម៌" [៣៩]។

៤៧. ហេតុដូច្នេះ ក្នុងអំឡុងរយៈពេលនៃសុពលភាពដែលគាត់បានចូលជំនួសតំណែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពេញសិទ្ធិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងមានសិទ្ធិអំណាច "បន្តបំពេញភារកិច្ចប្រចាំថ្ងៃ" [៤០] និងមានសិទ្ធិផងដែរក្នុងការពិចារណាឡើងវិញទៅលើសេចក្តីសម្រេចមុនៗ រួមទាំងសេចក្តីសម្រេចដែលបានចេញ បន្ទាប់មានសេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ ដរាបណាលក្ខខណ្ឌសម្រាប់ការពិចារណាឡើងវិញ ដូចដែលបានលើកឡើងខាងលើត្រូវបានបំពេញ [៤១]។

៤៨. បន្ថែមពីលើនេះ យើងសូមរំឭក និងឯកភាពតាមការកត់សម្គាល់របស់ចៅក្រម Downing និងចៅក្រម Lahuis នៅក្នុងយោបល់របស់ពួកគាត់ [៤២] ស្តីពីសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹងសេចក្តីសម្រេចស្តីពីការដាក់ឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួន ៣ ពាក់ព័ន្ធនឹងកំហុសអង្គច្បាប់ និងអង្គហេតុរបស់សហ

---

[39] សេចក្តីសម្រេចលើពាក្យសុំពិចារណាសារជាថ្មីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង, ឯកសារ C22/I/68, ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨, កថាខណ្ឌ ២៥ ដោយយោងលើច្បាប់យុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY)។

[40] សូមមើលជើងទំព័រ ២៧ ខាងលើ។

[41] យើងសង្កេតឃើញថាដីកាដែលត្រូវបានស្នើឡើងនោះ បានបំពេញលក្ខខណ្ឌសម្រាប់ការពិចារណាឡើងវិញនៅក្នុងកថាខណ្ឌ ៦-១១។

[42] សេចក្តីពិចារណារបស់អង្គជំនុំជម្រះទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់នឹង "សេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣, ឯកសារ D20/4/4, ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១, យោបល់បន្ថែមរបស់ចៅក្រម Lahuis និងចៅក្រម Downing។

ចៅក្រមស៊ើបអង្កេត និងការរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួនចំពោះការបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ។

៤៩. ដោយពិនិត្យទៅលើផលប្រយោជន៍នៃយុត្តិធម៌ និងហេតុផលទាំងប៉ុន្មានដូចមានបញ្ជាក់នៅក្នុងដីកាដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានស្នើសុំបំពេញកិច្ចស៊ើបសួរលើសំណុំរឿង ០០៣ យើងយល់ដូចគ្នាដែរថា ជាការចាំបាច់ដែលត្រូវបំពេញកិច្ចស៊ើបសួរឲ្យបានពេញលេញ ពាក់ព័ន្ធនឹងបទល្មើសធ្ងន់ធ្ងរទាំងប៉ុន្មាន ដូចមានចែងនៅក្នុងដីកាបញ្ជូនសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ និងធានាបាននូវការគោរពសិទ្ធិរបស់ភាគី និងជនរងគ្រោះ ពិសេសនៅពេលជនសង្ស័យពុំទាន់បានទទួលការជូនដំណឹងជាផ្លូវការអំពីការចោទប្រកាន់ ឬពុំទាន់ត្រូវបានឃុំខ្លួន នៅក្នុងមន្ទីរឃុំឃាំងបណ្ដោះអាសន្នតាមសំណើ។

## សន្និដ្ឋាន

៥០. ដោយហេតុថា អង្គបុរេជំនុំជម្រះពុំទាន់បានសម្រេចលើការខ្វែងយោបល់ ដែលស្ថិតនៅចំពោះមុខខ្លួន វិធាន៧២(៤)(ឃ) នៃវិធានផ្ទៃក្នុងណែនាំថា "ស្របតាមមាត្រា២៣ថ្មី នៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សេចក្ដីសម្រេចដែលមិនមានសំឡេងគាំទ្រមានន័យថា ដីកា ឬកិច្ចស៊ើបសួរដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតណាម្នាក់ ត្រូវមានសុពលភាពឬមានន័យថា ដីកា ឬកិច្ចស៊ើបសួរដែលបម្រុងនឹងធ្វើដោយសហចៅក្រមស៊ើបអង្កេតម្នាក់ ត្រូវតែយកមកអនុវត្ត"។ នៅក្នុងសំណុំរឿងនាពេលបច្ចុប្បន្ន ចំណុចនេះមានន័យថា ដីកាដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានស្នើឡើងនោះត្រូវតែយកមកអនុវត្តជាកំហិត។

ភ្នំពេញ ថ្ងៃទី xx ខែ កុម្ភៈ ឆ្នាំ ២០១២

ចៅក្រម Rowan DOWNING ចៅក្រម Chang-Ho CHUNG